*CAMBODIAN*

# អ្វីៗដែលតម្រូវឱ្យមានទៅក្នុងពេលបញ្ចប់ការសិក្សាសម្រាប់ថ្នាក់ឆ្នាំ 2009-2012

ការសំរេចគោលបំណងនៃការសិក្សាដោយបានទទួលវិញ្ញាបនបត្រ (CAA)

ការសំរេចគោលបំណងនៃការសិក្សាដោយបានទទួលវិញ្ញាបនបត្រ គឺការតម្រូវគ្រប់ៗរដ្ឋ និងមណ្ឌលសាលារៀនទាំងអស់ដែលតម្រូវឱ្យមានទៅក្នុងពេលបញ្ចប់ការសិក្សា, [1]មានរួមជាមួយគម្រោងការណ៍របស់រដ្ឋដែលត្រូវការឱ្យមានក៏រិតខ្ពស់បំផុត, និងពេលរៀននៅក្នុងសាលាវិទ្យាល័យនិងគម្រោងការណ៍ហួសលើសពីនឹងទៅទៀត ហើយនិង:

(1) ការប្រឡងជាប់ក្នុងចំណែកនៃផ្នែកអាននិងសរសេររបស់ WASL, ឬក៏

បន្ទាប់ពីការប្រឡង WASL ធ្លាក់ , ការជ្រើសរើសប្រឡងជាប់នៃផ្នែកសរសេរនិងអានផ្សេងៗទៀតដែលបានទទួលស្គាល់, រួមជាមួយមាន:

a. ផ្នែកអាន:

i. ត្រូវបាន 3 ពិន្ទុឡើងទៅនៅក្នុងការប្រឡងជាន់ខ្ពស់ (AP) មាន: ផ្នែកអក្សរសាស្រ, និងការតែងអត្ថបទ, ការសិក្សាអំពីសេដ្ឋកិច្ចទាំងមូល, ការសិក្សាអំពីសេដ្ឋកិច្ច, ចិត្តវិទ្យា, ប្រវត្តិសាស្ត្ររបស់សហរដ្ឋអាមេរិក, ប្រវត្តិសាស្ត្រពិភពលោក, រដ្ឋភិបាលនិងអ្នកប្រាជ្ញរបស់សហរដ្ឋអាមេរិក, ហើយនិងការប្រៀបធៀបរដ្ឋភិបាលនិងអ្នកប្រាជ្ញ, ឬក៏

ii. យ៉ាងតូចបំផុតត្រូវឱ្យមានពិន្ទុអានគ្រប់ខ្នាតរបស់ SAT ហើយនិង ACT, ណាមួយទៀត ក្រសួងផ្នែកអប់រំនៃការសិក្សារបស់រដ្ឋវ៉ាស៊ីនតោនស្តែតនិងប្រកាសប្រាប់ឱ្យដឹងថ្ងៃទី 1 ខែធ្នូ, ឆ្នាំ 2007 ខាងមុខនេះ

b. ផ្នែកសរសេរ:

i. ត្រូវបាន 3 ពិន្ទុឡើងទៅនៅក្នុងការប្រឡងជាន់ខ្ពស់ (AP) ផ្នែកភាសាអង់គ្លេសនិងការតែងអត្ថបទ, ឬ

ii. យ៉ាងូចបំផុតត្រូវឱ្យមានពិន្ទុនៃការអានគ្រប់ខ្នាតរបស់ SAT ហើយនិង ACT, ណាមួយទៀត ក្រសួងផ្នែកអប់រំនៃការសិក្សារបស់រដ្ឋវ៉ាស៊ីនតោនស្តែតនិងប្រកាសប្រាប់ឱ្យដឹងនៅថ្ងៃទី 1 ខែធ្នូ, ឆ្នាំ 2007 ខាងមុខនេះ

ហើយនិង

(2) ការប្រឡងជាប់ផ្នែកចំណោទលេខនៃការប្រឡង WASL , ឬក៏

បន្ទាប់ពីការប្រឡង WASL ធ្លាក់ , ការជ្រើសរើសប្រឡងជាប់នៃផ្នែកចំណោទលេខផ្សេងៗទៀតដែលបានទទួលស្គាល់, រួមជាមួយមាន:

a. ត្រូវមាន 19 ពិន្ទុឡើងទៅនៅក្នុងផ្នែកចំណោទលេខនៃការប្រឡងរបស់ ACT,

b. ត្រូវមាន 3 ពិន្ទុឡើងទៅនៅក្នុងការប្រឡងជាន់ខ្ពស់ (AP) នៃផ្នែកគណិតសាស្ត្រជាន់ខ្ពស់ ឬការប្រឡងស្ថិតិលេខ, ឬក៏

c. ត្រូវមាន 470 ពិន្ទុឡើងទៅនៅក្នុងផ្នែកចំណោទលេខនៃការប្រឡងរបស់ SAT

ឬក៏

(1) បន្ទាប់ពីការប្រឡង WASL ធ្លាក់, ការប្រៀបធៀបពិន្ទុ WASL, ដែលជាពិន្ទុរបស់សិស្សានុសិស្សណាដែលមាននៅក្នុងថ្នាក់ចំណោទលេខ ហើយ និងឬក៏ថ្នាក់ភាសាអង់គ្លេស បានធ្វើការប្រៀបធៀបទៅនិងពិន្ទុផ្សេងៗទៀតនៃសិស្សានុសិស្សណាដែលបានយកថ្នាក់ៗដូចគ្នា **ហើយដែល**

---

[1] ក្រសួងផ្នែកអប់រំនៃការសិក្សា និងមានគម្រោងការណ៍ឱ្យសិស្សានុសិស្សទាំងអស់បន្ថែមពិន្ទុនៅក្នុងផ្នែកចំណោទលេខបន្ថែមទៀត ដែលមានពីរពិន្ទុត្រូវតែឱ្យមានបីពិន្ទុ, មានន័យថាសិស្សានុសិស្សម្នាក់នេះនិងត្រូវការប្រាំមួយថ្នាក់នៃថ្នាក់ចំណោទលេខ ដែលជាតម្រូវការឱ្យបាននៅក្នុងពេលកំពុងរៀននៅក្នុងថ្នាក់ទី 9th, ថ្នាក់ទី 10th , និងថ្នាក់ទី 11th នៃក៏រិតថ្នាក់របស់ (GLEs) មុនឡើងថ្នាក់ទី 12th។

**និង** បានប្រឡង WASL ជាប់។ ការជ្រើសរើសនេះគឺសម្រាប់តែសិស្សានុសិស្សរៀនថ្នាក់ទី 12th ទេ ដែលសិស្សនោះមានពិន្ទុមធ្យមភាគសារុបយ៉ាងតូចបំផុត 3.2 ដែលមាននៅក្នុងក៏រិតមាត្រា 4.0។

(1) បន្ទាប់ពីការប្រឡង WASL ធ្លាក់ , បានធ្វើការប្រមូលផ្តុំយកកិច្ចការទាំងអស់នោះធ្វើជាជំណាង ទុកសម្រាប់បញ្ជូនទៅរដ្ឋដើម្បីឱ្យរដ្ឋឱ្យពិន្ទុ (ការប្រមូលផ្តុំសម្រាប់ទុកជាភត្តុតាង)។

## ការទទួលសញ្ញាបត្រ៏

សម្រាប់សិស្សានុសិស្សណាដែលបានបំពេញ CAA ទាំងអស់ហើយ, ប៉ុន្តែគ្មានសមត្ថភាពប្រឡងផ្នែកចំណោទលេខរបស់ WASL ជាប់ ឬមុខវិជ្ជាផ្សេងៗទៀត. ពួកគេអាចទទួលបានសញ្ញាបត្រ៏វិទ្យាល័យ ហើយបានបញ្ចប់សិក្សា ដោយសារជាប់មួយថ្នាក់នៃផ្នែកចំណោទលេខ ឬបានពិន្ទុមកពីការសិក្សាថ្នាក់ CTE (ស្មើពីរថ្នាក់) ហើយនិងបានប្រឡង WASL សារជាថ្មីម្តងទៀត។ សិស្សានុសិស្សទាំងអស់ត្រូវតែប្រឡងជាប់ថ្នាក់ចំណោទលេខ, មិនមែនតែ WASL ទេ, ដើម្បីឱ្យបានទទួលសញ្ញាបត្រ៏។

ហើយបើសិនសិស្សប្រឡងជាប់ផ្នែកចំណោទលេខរបស់ WASL នៅក្នុងពេលប្រឡងសារជាថ្មីម្តងទៀតនេះ, ពួកគេមិនត្រូវការយកថ្នាក់ចំណោទលេខឬថ្នាក់សិក្សា CTE ទេ។ ពួកគេអាចនិងបានទទួលវិញ្ញាបមបត្រ៏ មិនមែនសញ្ញាបត្រ៏ទេ។

## ការទទួលវិញ្ញាបមបត្រ៏ដែលជាកម្មសិទ្ធរបស់ខ្លួនផ្ទាល់ (CIA)

CIA នេះគឺសម្រាប់សិស្សានុសិស្សរៀននៅក្នុងកម្មវិធីពិសេស សិស្សណាដែលមិនអាចប្រឡង WASL បាន (មានឬគ្មានការសម្រួលផ្សេងៗ) ដែលសិស្សនោះមានសិទ្ធគ្រប់គ្រាន់ទទួលអ្វីៗមុនពេលបញ្ចប់ការសិក្សាមកពីរដ្ឋនិងមណ្ឌល <u>ហើយនិង</u>

(1) បានបំពេញ WASL-Modified (WASL-MO) ឬក៏ WAAS-Portfolio ដែលមាននៅក្នុងថ្នាក់ទី 9 ឬថ្នាក់ទី 10 <u>ឬក៏</u>

(2) បានយកថ្នាក់ Developmentally Appropriate WASL (WASS-DAW) ដែលមាននៅក្នុងថ្នាក់ទី 11 និងថ្នាក់ទី 12។

## វិញ្ញាបមបត្រ៏នៃការវត្តមាន

សម្រាប់សិស្សានុសិស្សរៀននៅក្នុងកម្មវិធីពិសេស សិស្សណាដែលមិនអាចបំពេញការតម្រូវរបស់ CIA, មណ្ឌលអាចឱ្យវង្វង់ដល់ពួកគេជាវិញ្ញាបមបត្រ៏នៃការវត្តមាន។ ឱ្យស្របទៅតាម “ច្បាប់ Kevin’s”, មណ្ឌលត្រូវតែឱ្យសិទ្ធដល់សិស្សានុសិស្សដែលរៀននៅក្នុងកម្មវិធីពិសេស សិស្សណាដែលរៀននៅក្នុងកម្មវិធីសិក្សាពិសេសដោយខ្លួនឯងផ្ទាល់ (IEP) ដែលនោះបានដាក់បញ្ញត្តឱ្យសិក្សាបន្តនៅក្នុងកម្មវិធីសិសេស ឬក៏ទាក់ទងទៅនិងការបម្រើសិស្សានុសិស្សដែលមានអាយុ 18 ឆ្នាំ ទៅ 21 ឆ្នាំ (ទោះបីពួកគេនោះមិនអាចបំពេញគម្រោងការណ៏របស់ CIA ក៏ដោយ) ដើម្បីឱយពួកគេអាចចូលរួមនៅក្នុងពិធីទទួលសញ្ញាបត្រ៏ ដែលពួកគេបានបញ្ចប់ការសិក្សាបួនឆ្នាំនៅក្នុងសាលាវិទ្យាល័យ។ [2]សិស្សានុសិស្សប្រហែលអាចជ្រើសរើសចូលរួមនៅក្នុងពិធីចែកវិញ្ញាបមបត្រ៏នៃការវត្តមាននៅពេលណាពួកគេបានបំពេញ IEP នៃគោលបំណងរបស់ពួកគេ ហើយនិងឬក៏ពេលណាដែលពួកគេគ្រប់អាយុ 21 ហើយ។

---

[2] សិស្សានុសិស្សណាដែលរៀននៅក្នុងកម្មវិធីពិសេស <u>មិនអាចមានសិទ្ធ</u> ចូលរួមនៅក្នុងពិធីចែកសញ្ញាបត្រ៏ឬវិញ្ញាបមបត្រ៏ជារៀងរាល់ឆ្នាំបន្ទាប់មក។ ទោះយ៉ាងណាក៏ដោយ, ពួកគេត្រូវតែមានសិទ្ធចូលរួមនៅក្នុងពិធីចែកសញ្ញាបត្រ៏ឬវិញ្ញាបមបត្រ៏ម្តងទៀត បន្តបន្ទាប់មកទៀតបើសិនណាពួកគេបានបំពេញគម្រោងការណ៏របស់ CIA ហើយបន្ទាប់ពីពួកគេបានបញ្ចប់សិក្សាបួនឆ្នាំនៅក្នុងវិទ្យាល័យ។